***HỎI - ĐÁP***

**Điều tra thu thập thông tin về thực trạng**

**kinh tế - xã hội của 53 dân tộc thiểu số năm 2019** ***(Đọc xướng Nam – Nữ 2 lần)***

***Giọng nữ hỏi – Nam đáp***

***Đổi giọng (Nam – Nữ)***

**Nam:** លោកអ្នកនាងនិងមិត្តអ្នកស្តាប់ជាទីមេត្រី!

ដើម្បីឆ្លើយតបប្រព័ន្ធពត៍មាន តួលេខស្ថិតិឆ្លុះបញ្ចាំងអំពីស្ថានភាពសេដ្ឋកិច្ច - សង្គមនៃ 53 ជនជាតិភាគតិច បំរើសកម្មភាពគ្រប់គ្រងរបស់រដ្ឋស្តីពីការងារជនជាតិ ក៏ដូចជាវាយតម្លៃនិងកសាងបណ្តាគោលនយោបាយជូនជនរួមជាតិភាគតិចនៃប្រទេសយើង, ថ្ងៃទី 05 ខែមករា ឆ្នាំ 2015, លោកនាយករដ្ឋមន្ត្រីរដ្ឋាភិបាល បានប្រកាសឲ្យប្រើសេចក្តីសំរេចលេខ 02/QĐ-TTg ស្តីអំពីការពិនិត្យយល់ព្រមគំរោងការជំរឿន, ប្រមូលយកពត៍មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច - សង្គមនៃ 53 ជនជាតិភាគតិច។

**Nữ:** អនុវត្តសេចក្តីសំរេចលេខ 02/QĐ-TTg, អគ្គនាយកដ្ឋានស្ថិតិរួបរួមជាមួយគណៈកម្មាធិការជនជាតិអនុវត្តការជំរឿនប្រមូលយកពត៍មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច - សង្គមនៃ 53 ជនជាតិភាគតិចលើកទី២ក្នុងខែតុលាឆ្នាំ 2019។

អគ្គនាយកដ្ឋានស្ថិតិនិងគណៈកម្មាធិការជនជាតិ សូមឧទ្ទេសនាមជូនលោកអ្នកនាងនូវខ្លឹមសារមួយចំនួននៃការជំរឿនប្រមូលយកពត៍មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច - សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 តាមរយៈនិទ្ទេសបទ “សំណួរនិងចម្លើយ”។

**(Nữ hỏi – Nam đáp. Trong trường hợp giọng nữ tốt hơn có thể đổi vế)**

**1. សំណួរទី១**:

**គោលបំណងនៃការជំរឿនប្រមូលយកពត៌មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច - សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 គឺអ្វីទៅ?**

**ចម្លើយៈ**

ប្រទេសយើងមាន 54 ជនជាតិ ក្នុងនោះជនជាតិ Kinh មានអត្រាច្រើន, 53 ជនជាតិដែលនៅសេសសល់គឺជនជាតិភាគតិច។ ជនរួមជាតិបណ្តាជនជាតិភាគតិចនៅប្រទេសយើង ភាគច្រើនរស់នៅតំបន់ភ្នំ តំបន់ឆ្ងាយដាច់ស្រយ៉ាល និង តំបន់ព្រំដែន កន្លែងមានទីតាំងយុទ្ធសាស្ត្រ ប៉ុន្តែជួបការលំបាកខាងសេដ្ឋកិច្ច-សង្គម។ ក្នុងអំឡុងឆ្នាំកន្លងមក បក្សនិងរដ្ឋមានគោលនយោបាយជាច្រើន ជួយជនរួមជាតិភាគតិចអភិវឌ្ឍន៍សេដ្ឋកិច្ច បំបាត់គ្រោះអត់ឃ្លាន កាត់បន្ថយភាពក្រីក្រ រក្សានិងពង្រីកអត្តសញ្ញាណជាតិរបស់ខ្លួន។ យ៉ាងណាមិញ ពត៌មានសម្រាប់បំរើការវាយតម្លៃស្ថានភាព ត្រួសត្រាយគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមតំបន់ជនជាតិភាគតិច កាត់បន្ថយភាពក្រីក្រក្នុងជនរួមជាតិភាគតិចគឺនៅខ្វះ។ ហេតុដូច្នេះហើយ ជំរឿនប្រមូលយកពត៌មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 គឺដើម្បីប្រមូលយកពត៌មានស្តីអំពីប្រជាសាស្ត្រ លំនៅដ្ឋាន និងលក្ខណៈសម្បត្តិរស់នៅនៃគ្រួសារជនជាតិភាគតិច និងបណ្តាលក្ខណៈសម្បត្តិសេដ្ឋកិច្ច-សង្គមផ្សេងៗ សំដៅឆ្លុះបញ្ចាំងស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិច ដើម្បីរៀបរៀងបណ្តាសន្ទស្សន៍ស្ថិតិអំពីជនជាតិ បំរើការកសាងនិងត្រួសត្រាយគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមឲ្យបណ្តាតំបន់ជនជាតិភាគតិចដំណាក់កាល 2021 - 2025;

**2. សំណួរទី២**:

**តើស្ថាប័នណាទទួលខុសត្រូវអនុវត្តការជំរឿនប្រមូលយកពត៌មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019?**

**ចម្លើយៈ**

យោងតាមសេចក្ដីសំរេចលេខ 02/QĐ-TTg ចុះហត្ថលេខាកាលពីថ្ងៃទី 05/01/2015 របស់លោកនាយករដ្ឋមន្ត្រីរដ្ឋាភិបាល ស្ដីអំពីការពិនិត្យយល់ព្រមគំរោងការជំរឿនប្រមូលយកពត៌មានស្ដីពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិច អគ្គនាយកដ្ឋានស្ថិតិទទួលខុសត្រូវបង្គាប់ការ រួបរួមជាមួយគណៈកម្មាធិការជនជាតិ និងបណ្ដាក្រសួង ផ្នែក ស្ថាប័នពាក់ព័ន្ធរៀបចំជំរឿនប្រមូលយកពត៌មាន។ គណៈកម្មាធិការជនជាតិតាមដាន ឃ្លាំមើល ទទួលយកនិងប្រើប្រាសពត៌មាន តួលេខនៃការជំរឿនពីអគ្គនាយកដ្ឋានស្ថិតិ។

**3. សំណួរទី៣៖**

**តើការជំរឿនបានអនុវត្តយោងទៅតាមដំណាក់កាលនឹងពេលវេលាណាខ្លះ?**

**ចម្លើយ៖**

ថិរវេលាជំរឿនគឺ ម៉ោង 0 ថ្ងៃទី 01/10/2019 ។

ថិរវេលាប្រមូលយកពត៌មាននៅតាមគ្រួសារជនជាតិភាគតិច និងនៅគណៈកម្មាធិការប្រជាជនថ្នាក់ឃុំ ចាប់ផ្ដើមពីថ្ងៃទី 01/10/2019, បញ្ចប់នាថ្ងៃទី 31/10/2019 ។

**4. សំណួរៈទី៤**

**តើអង្គភាពជំរឿនក្នុងការជំរឿនប្រមូលយកពត៌មានស្ដីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 គឺអ្វីទៅ?**

**ចម្លើយ៖**

អង្គភាពជំរឿនរួមមាន៖

- ក្រុមគ្រួសារជនជាតិភាគតិច (ឬនៅហៅថាគ្រួសារជនជាតិភាគតិច)។ គ្រួសាររួមមាន មនុស្សម្នាក់រស់នៅ ប្រជុំជីវភាពដោយឡែក ឬមនុស្សមួយក្រុមរស់នៅ ប្រជុំជីវភាពជាមួយគ្នា។ ចំពោះគ្រួសារមានមនុស្សពី២នាក់ឡើងទៅ សមាជិក

ក្នុងគ្រួសារ អាចមានឬគ្មានមូលនិធិចំណូល ចំណាយរួម; មានឬគ្មានទំនាក់ទំនងសាច់សារលោហិត, អាពាហ៍ពិពាហ៍ឬចិញ្ចឹមបីបាច់ថែរក្សា; ឬទាំង២ករណីដែលទើបតែពោលមកនេះ;

- គណៈកម្មាធិការប្រជាជនឃុំ សង្កាត់ ទីរួមស្រុក យោងតាមសេចក្តីសំរេចលេខ 582/QĐ-TTg ចុះហត្ថលេខាកាលពីថ្ងៃទី 28/4/2017 និងសេចក្តីសំរេចលេខ 103/QĐ-TTg ចុះហត្ថលេខាកាលពីថ្ងៃទី 22/01/2019 របស់លោកនាយករដ្ឋមន្ត្រីរដ្ឋាភិបាល; បណ្តាឃុំមិនចំណុះតំបន់ដែលទើបតែពោលមកនេះ ប៉ុន្តែមានភូមិសាស្ត្រតំបន់ជនជាតិភាគតិច។

**5. សំណួរទី៥៖**

**ក្នុងការជំរឿនលើកនេះ, តើនិយមន័យភូមិសាស្ត្រតំបន់ជនជាតិភាគតិចបានយល់ដូចម្តេចទៅ?**

**ចម្លើយ៖**

ក្នុងការជំរឿនលើកនេះ ភូមិសាស្ត្រតំបន់ជនជាតិភាគតិចបានកំណត់ថា ជាភូមិសាស្ត្រមានចំនួនជនជាតិភាគតិចកំពុងរស់នៅដោយអត្រាពី 30% ឡើងទៅ បើប្រៀបធៀបនឹងចំនួនប្រជាជននៃភូមិសាស្ត្រនោះ។

**6. សំណួរទី៦៖**

**តើយ៉ាងណាទើបហៅថាគ្រួសារជនជាតិភាគតិច?**

**ចម្លើយ៖**

ក្នុងការជំរឿនប្រមូលយកពត៍មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019, គ្រួសារជនជាតិភាគតិចបានកំណត់ថា ជាគ្រួសារប្រជាជនឆ្លើយតបបានយ៉ាងហោចណាស់ពី១ដល់៣លក្ខណៈសម្បត្តិដូចតទៅនេះ៖

ទី(1)គឺ ម្ចាស់គ្រួសារគឺជនជាតិភាគតិច;

ទី(2)គឺ ប្រពន្ធឬប្ដីនៃម្ចាស់គ្រួសារ ជាជនជាតិភាគតិច;

ទី(3)គឺ គ្រួសារមានចំនួនសមាជិកជាជនជាតិភាគតិចដោយអត្រាពី 50% ឡើងទៅ។

**7. សំណួរទី៧៖**

**ការជំរឿនប្រមូលយកពត៍មានស្ដីពំអីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 បានអនុវត្តក្នុងទ្រង់ទ្រាយណាខ្លះ?**

**ចម្លើយ៖**

ការជំរឿនប្រមូលយកពត៍មានស្ដីពំអីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 បានអនុវត្តនៅ 54 ខេត្ត ក្រុងក្រោមឱវាទមជ្ឈឹម រួមមាន 51 ខេត្តមានឃុំចំណុះតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំយោងតាមសេចក្ដីសំរេចលេខ 582/QĐ-TTg ចុះហត្ថលេខាថ្ងៃទី 28/4/2017 និងសេចក្ដីសំរេចលេខ 103/QĐ-TTg ចុះហត្ថលេខាថ្ងៃទី 22/01/2019 របស់លោកនាយករដ្ឋមន្ត្រីរដ្ឋាភិបាល និងមូលដ្ឋានចំនួន 03 មានបណ្ដាឃុំមានជនរួមជាតិភាគតិចរស់នៅច្រើនកុះករ ជាទីក្រុង Hồ Chí Minh, ខេត្ត Long An និងខេត្ត Bình Dương។

**8. សំណួរទី៨៖**

**ក្នុងការជំរឿននេះ គឺគ្រួសារជនជាតិភាគតិចទាំងអស់សុទ្ធតែបានជំរឿនមែនទេ?**

**ចម្លើយ៖**

ចំពោះជនជាតិភាគតិចមានចំនួនប្រជាជនក្រោម 10 ពាន់នាក់ក្នុងទូទាំងប្រទេស និងរស់នៅក្នុងភូមិសាស្ត្រតំបន់ជនជាតិភាគតិច គឺធ្វើការជំរឿនទាំងអស់នូវចំនួនគ្រួសារចំណុះក្រុមជនជាតិភាគតិចនេះ; បណ្ដាជនជាតិភាគតិចផ្សេងដែលមានមនុស្សពី 10ពាន់នាក់ឡើងទៅរស់នៅក្នុងភូមិសាស្ត្រតំបន់ជនជាតិ

ភាគតិច គឺបានជំរឿនតាមបែបជ្រើសរើសគំរូដំណាង។ មានតែគ្រួសារជនជាតិភាគតិចបានជ្រើសរើសជាគំរូដំណាងទេ ទើបបានជំរឿន បណ្ដាគ្រួសារជនជាតិភាគតិចរស់នៅក្រៅតំបន់ជនជាតិភាគតិច ឬក្នុងតំបន់ជនជាតិភាគតិច ប៉ុន្តែមិនបានជ្រើសរើសធ្វើជាគំរូដំណាង គឺមិនចំណុះទ្រង់ទ្រាយជំរឿនទេ។

**9. សំណួរទី៩៖**

**ក្នុងការជំរឿននេះ បណ្ដាឃុំ សង្កាត់ ទីរួមស្រុកគ្មានភូមិសាស្រ្តតំបន់ជនជាតិភាគតិច ប៉ុន្តែជាឃុំ សង្កាត់ ទីរួមស្រុកចំណុះតំបន់លេខ III, II, I តាមសេចក្ដីសំរេចលេខ 582/QĐ-TTg ចុះហត្ថលេខាថ្ងៃ 28/4/2017 និង សេចក្ដីសំរេចលេខ 103/QĐ-TTg ចុះហត្ថលេខាថ្ងៃ ngày 22/01/2019 របស់លោកនាយករដ្ឋមន្ត្រីរដ្ឋាភិបាល តើបានជំរឿនដោយប័ណ្ណជំរឿនរបស់ឃុំដែរឬទេ បើបាតើដោយសារមូលហេតុអ្វីទៅ?**

**ចម្លើយ៖**

បណ្ដាឃុំ សង្កាត់ ទីរួមស្រុកគ្មានភូមិសាស្រ្តតំបន់ជនជាតិភាគតិច ប៉ុន្តែជាឃុំ សង្កាត់ ទីរួមស្រុកចំណុះតំបន់លេខ III, II, I តាមសេចក្ដីសំរេចលេខ 582/QĐ-TTg ចុះហត្ថលេខាថ្ងៃ 28/4/2017 និងសេចក្ដីសំរេចលេខ 103/QĐ-TTg ចុះហត្ថលេខាថ្ងៃ 22/01/2019 របស់លោកនាយករដ្ឋមន្ត្រីរដ្ឋាភិបាល គឺបានជំរឿនដោយប័ណ្ណជំរឿនរបស់ឃុំ ដើម្បីក្ដាប់យកពត៌មានស្ដីអំពីស្ថានភាពហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច - សង្គមនៃបណ្ដាតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ ជួយឲ្យបក្សនិងរដ្ឋកសាងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមនៅបណ្ដាមូលដ្ឋានដែលជួបការលំបាកច្រើននេះ។

**10. សំណួរទី១០៖**

**ការជំរឿនប្រមូលយកពត៌មានស្ដីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 ប្រមូលយកពត៌មានអ្វីខ្លះ?**

**ចម្លើយៈ**

ជំរឿនប្រមូលយកពត៌មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 នឹងប្រមូលយកពត៌មានដូចតទៅៈ

***ចំពោះគ្រួសារជនជាតិភាគតិច នឹងប្រមូលយកបណ្តាក្រុមពត៌មានសំខាន់ៗដូចតទៅៈ***

ទី1. ពត៌មានរួមស្តីអំពីប្រជាជន រួមមានៈ ចំនួនមនុស្ស ភេទ វ័យអាយុ ជនជាតិ សាសនា ស្ថានភាពប្រើប្រាស់ធានារ៉ាប់រងសុខាភិបាល ចាក់វ៉ាក់សាំងបង្ការឲ្យកុមារ ស្ថានភាពពិការ ស្ថានភាពចំណាកស្រុក ចំណេះដឹងអប់រំនិងបណ្តុះបណ្តាល លទ្ធភាពនិយាយស្តីនិងចេះសរសេរអក្សរសាកល អក្សរជនជាតិ ស្ថានភាពអាពាហ៍ពិពាហ៍ ពលកម្មការធ្វើ;

ទី2. ពត៌មានស្តីអំពីប្រវត្តិរូបចាប់កំណើតរបស់នារីភេទជាអនីតិជន មានអាយុពី 10-14 ឆ្នាំ និងនារីភេទមានអាយុពី 15-49 ឆ្នាំ;

ទី3. ពត៌មានស្តីអំពីចំនួនមនុស្សស្លាប់នៃគ្រួសារ;

ទី4. ពត៌មានស្តីអំពីលំនៅដ្ឋាន និងលក្ខណៈប្រជុំជីវភាពនៃគ្រួសារ;

ទី5. ពត៌មានស្តីអំពីចំនួននិងសត្វចិញ្ចឹមគ្រប់ប្រភេទនៃគ្រួសារ;

ទី6. ពត៌មានស្តីអំពីដីលំនៅដ្ឋាននិងដីបង្កបង្កើនផលនៃគ្រួសារ;

ទី7. ពត៌មានស្តីអំពីតម្រូវការបុលទុនអនុគ្រោះនៃគ្រួសារ;

ទី8. ពត៌មានស្តីអំពីស្ថានភាពវប្បធម៌-សង្គម និងបង្ខិតចូលជិតបណ្តាសេវាកម្មសាធារណៈនៃគ្រួសារ។

***ចំពោះគណៈកម្មាធិការប្រជាជនថ្នាក់ឃុំ នឹងប្រមូលយកពត៌មានដូចតទៅៈ***

- ពត៌មានរួមស្តីអំពីលក្ខណៈសម្បត្តិរបស់ឃុំ;
- ពត៌មានស្តីអំពីហេដ្ឋារចនាសម្ព័ន្ធនិងពត៌មាន;
- ពត៌មានស្តីអំពីសាលារៀននិងចំណេះដឹងរបស់គ្រូបង្រៀន;
- ពត៌មានស្តីអំពីផ្សារ មណ្ឌលសុខភាព និងអនាម័យបរិស្ថាន;

- ពត៍មានស្តីអំពីចំនួនកម្មាភិបាល និយោជិកថ្នាក់ឃុំ;
- ពត៍មានស្តីអំពីសាសនា និងជំនឿសាសនា។

**11. សំណួរទី១១៖**

**ជំរឿនប្រមូលយកពត៍មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 ចំណុះប្រភេទជំរឿនស្ថិតិណាទៅ?**

**ចម្លើយ ៖**

ជំរឿនប្រមូលយកពត៍មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 ជាការជំរឿនជ្រើសរើសគំរូដំណាង។ ទ្រង់ទ្រាយគំរូដំណាងបានបែងចែកធានាក់រិតដំណាងដល់ថ្នាក់ស្រុកស្តីអំពីសន្ទស្សន៍ប្រជាសាស្ត្រមួយចំនួននៃបណ្តាជនជាតិនិយាយរួម និងជនជាតិភាគតិចនិមួយៗជាសំខាន់ក្នុងស្រុកនិយាយដោយឡែក។ ដោយឡែកចំពោះបណ្តាជនជាតិភាគតិចមានចំនួនប្រជាជនក្រោម 10.000 នាក់ក្នុងទូទាំងប្រទេស នឹងធ្វើការជំរឿនទាំងអស់នូវចំនួនគ្រួសារចំណុះក្រុមជនជាតិភាគតិចនេះនៅភូមិសាស្ត្រតំបន់ជនជាតិភាគតិច។

**12. សំណួរទី១២៖**

**បណ្តាវិធីសាស្ត្រប្រមូលយកពត៍មានក្នុងការជំរឿនប្រមូលយកពត៍មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 គឺអ្វីទៅ?**

**ចម្លើយ៖**

ជំរឿងប្រមូលយកពត៍មានស្តីអំពីស្ថានភាព សេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 ប្រើប្រាស់វិធីសាស្ត្រ២យ៉ាងដើម្បីប្រមូលយកពត៍មាន ដូចតទៅ៖

ទី១(*) ចំពោះគ្រួសារប្រជាជន: អនុវត្តវិធីសាស្ត្រសំភាសន៍ផ្ទាល់។ បុគ្គលិកជំរឿនស្ថិតិនិងចុះទៅដល់គ្រួសារនិមួយៗ ដើម្បីសាកសួរអ្នកផ្តត់ផ្តង់ពត៍មាន និង

កត់ត្រាគ្រប់គ្រាន់នូវចម្លើយទាំងអស់ចូលទៅក្នុងប័ណ្ណជំរឿនអេឡិកត្រូនិកដែលមានក្នុងឧបករណ៍ទូរស័ព្ទចល័ត – កុំព្យូទ័រ ឬទូរស័ព្ទឈ្លាសវៃ។

ទី២(*) ចំពោះគណៈកម្មាធិការប្រជាជនឃុំសង្កាត់ទីរួមស្រុក: អនុវត្តវិធីសាស្ត្រផ្តត់ផ្គង់ពត៌មានតាមបណ្តាញ។ ដំណាងគណៈកម្មាធិការប្រជាជនឃុំសង្កាត់ទីរួមស្រុក ឬអ្នកយល់ច្បាស់ពត៌មានរបស់ឃុំ សង្កាត់ ទីរួមស្រុក នឹងផ្តត់ផ្គង់ពត៌មានដោយខ្លួនឯងតាមរយៈប័ណ្ណជំរឿនរបស់ឃុំនៅលើទំព័រពត៌មានអេឡិកត្រូនិកនៃការជំរឿនជនជាតិភាគតិច។ អ្នកផ្តត់ផ្គង់ពត៌មានចូលប័ណ្ណជំរឿនរបស់ឃុំនឹងបានជូនគណនីនិងលេខសម្ងាត់ដើម្បីចូលបណ្តាញនិងផ្តត់ផ្គង់ពត៌មាន។

**13. សំណួរទី១៣៖**

**ចំពោះអ្នកអវត្តមានក្នុងអំឡុងពេលជំរឿន តើប្រមូលយកពត៌មានដោយវិធីណាទៅ?**

**ចម្លើយ៖**

ម្ចាស់គ្រួសារឬអ្នកយល់ច្បាស់អំពីសមាជិកក្នុងគ្រួសារ នឹងផ្តត់ផ្គង់ពត៌មានអំពីអ្នកអវត្តមានដល់បុគ្គលិកជំរឿនស្ថិតិ បើម្ចាស់គ្រួសារមិនក្តាប់បានពត៌មានអំពីមុខរបរ ចំណេះដឹងអប់រំ បណ្តុះបណ្តាល ជំនាញបច្ចេកទេស ឬកន្លែងធ្វើការនៃអ្នកអវត្តមាន និងពត៌មានផ្សេងៗទេនោះ គឺបុគ្គលិកជំរឿនស្ថិតិអាចទំនាក់ទំនងជាមួយអ្នកអវត្តមាននោះតាមរយៈទូរស័ព្ទដើម្បីប្រមូលយកពត៌មាន។

**14. សំណួរទី១៤៖**

**ច្បាប់ជាធរមាននៃប្រទេសយើង បញ្ញាតិអំពីសិទ្ធិនិងកាតព្វកិច្ចរបស់អង្គការ បុគ្គលបានជំរឿនស្ថិតិដូម្តេចទៅ?**

**ចម្លើយ៖**

យោងតាមមាត្រា 33 នៃច្បាប់ស្ថិតិបញ្ញាតិអំពីសិទ្ធិនិងកាតព្វកិច្ចរបស់អង្គការ បុគ្គលបានជំរឿនស្ថិតិដូចតទៅ ៖

ទី1. អង្គការ បុគ្គលបានជំរឿនស្ថិតិមានបណ្ដាសិទ្ធិដូចតទៅនេះ៖

ក) បានជូនដំណឹងអំពីសេចក្ដីសំរេច គោលបំណង សំណួមពរ ទ្រង់ទ្រាយខ្លឹមសារជាសំខាន់ និងពេលកំណត់នៃការជំរឿន;

ខ) បានធានាពត៌មានដែលផ្ដត់ផ្ដង់ឲ្យបុគ្គលឹកជំរឿនស្ថិតិតាមបញ្ញាតិត្រង់មាត្រា 57 នៃច្បាប់នេះ;

គ) តវ៉ា ថ្កោលទោសអំពើបំពានច្បាប់ជំរឿនស្ថិតិ។

ទី2. អង្គការ បុគ្គលបានជំរឿនស្ថិតិមានកាតព្វកិច្ចដូចតទៅ៖

ក) ផ្ដត់ផ្ដង់ពត៌មានស្មោះត្រង់ ប្រាកដប្រជា គ្រប់គ្រាន់និងត្រឹមត្រូវតាមពេលវេលាសំណួមពររបស់បុគ្គលឹកជំរឿនស្ថិតិ ឬស្ថាប័នធ្វើការជំរឿនស្ថិតិ;

ខ) មិនត្រូវបដិសេធន៍ ឬរាំងការផ្ដត់ផ្ដង់ពត៌មានជំរឿនស្ថិតិ;

គ) យល់ព្រមនូវការជំរឿនរបស់ស្ថាប័នធ្វើការជំរឿនស្ថិតិ និងអធិការកិច្ចជំនាញស្ថិតិអំពីពត៌មានដែលបានផ្ដត់ផ្ដង់។

**15. សំណួរទី១៥**:

**រាល់ពត៌មានបុគ្គលដែលប្រជាជនផ្ដត់ផ្ដង់ឲ្យបុគ្គលឹកជំរឿនស្ថិតិ បានរក្សាសម្ងាត់ដែរឬទេ តើមានប្រើប្រាស់ដើម្បីគោលបំណងផ្សេងដែរឬទេ?**

**ចម្លើយ៖**

មាត្រា 57 នៃច្បាប់ស្ថិតិ បញ្ញាតិអំពីភាពសម្ងាត់ពត៌មានស្ថិតិរបស់រដ្ឋដូចតទៅ៖

ទី1. ពត៌មានស្ថិតិគ្រប់ប្រភេទរបស់រដ្ឋ ត្រូវបានរក្សាដោយភាពសម្ងាត់រួមមាន៖

ក) ពត៌មានភ្ជាប់តាមឈ្មោះ អាស័យដ្ឋានជាក់ស្តែងនៃអង្គការ បុគ្គលនិមួយៗ វៀរលែងតែអង្គការ បុគ្គលនោះយល់ព្រម ឬច្បាប់មានកំណត់ផ្សេង;

ខ) ពត៌មានស្ថិតិមិនទាន់បានអ្នកមានសមត្ថកិច្ចប្រកាស;

គ) ពត៌មានស្ថិតិមិនទាន់ចំណុះបញ្ជីសម្ងាត់របស់រដ្ឋ។

ទី2. ការរក្សាភាពសម្ងាត់ ពត៌មានស្ថិតិរបស់រដ្ឋ បានអនុវត្តតាមបញ្ញាតិនៃច្បាប់។

ហេតុដូច្នេះហើយ ពត៌មានបុគ្គលដែលប្រជាជនផ្តត់ផ្តង់ក្នុងការជំរឿនប្រមូលយកពត៌មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចបានប្រើប្រាស់សម្រាប់បូកសរុបជាមួយពត៌មាននៃគ្រប់ជាន់ថ្នាក់ដូចជាៈ ស្រុក ខេត្ត និងមជ្ឈឹម ពោលគឺមិនប្រើប្រាស់សម្រាប់គោលបំណងណាផ្សេងឡើយ។

**16. សំណួរទី១៦ៈ**

**ពេលចង់ស្វែងយល់បន្ថែមពត៌មានពាក់ព័ន្ធដល់ការជំរឿនប្រមូលយកពត៌មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 តើអាចសួរនៅទីណាទៅ?**

**ចម្លើយៈ**

ករណីចង់ស្វែងយល់ពត៌មានពាក់ព័ន្ធដល់ការជំរឿនប្រមូលយកពត៌មានស្តីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 លោកអ្នកអាចទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានស្ថិតិតាមអាស័យដ្ឋានដូចតទៅៈ

អាស័យដ្ឋាន: លេខ 54, Nguyễn Chí Thanh, ខ័ណ្ឌ Đống Đa, ក្រុង Hà Nội។

ឬទូរស័ព្ទមកកាន់លេខ: 18009050.

Email: TKDSLD@gso.gov.vn.

អគ្គនាយកដ្ឋានស្ថិតិស្វាគមន៍ស្មារតីសហប្រតិបត្តិការ និងការជួយផ្តងផ្តើមពីសំណាក់ប្រជាជន រដ្ឋអំណាចគ្រប់ជាន់ថ្នាក់ និងបណ្តាអង្គភាពជំរឿន ដើម្បីការ

ជំរឿនប្រមូលយកពត៌មានស្ដីអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៃ 53 ជនជាតិភាគតិចឆ្នាំ 2019 អនុវត្តបានសំរេចជោគជ័យ សូមអរគុណ៕